ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត

ខេត្តកំពត ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥

សូមគោរព :

- ឯកឧត្តម ខូយ យុនហ៊្វរ អភិបាល នៃគណៈអភិបាលខេត្តកំពត
- ឯកឧត្តម កែន សត្ថា អភិបាល នៃគណៈអភិបាលខេត្តកែប
- ឯកឧត្តម អ៊ឹង ម៉េងហួរ ប្រធានក្រុមប្រឹក្សាខេត្តកំពត
- ឯកឧត្តម សំ សាវីន ប្រធានក្រុមប្រឹក្សាខេត្តកែប
- លោក Hervé Dallerac ទីប្រឹក្សាទូទៅថ្មីរបស់ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា
- លោក Dong Hyun Choi ទីប្រឹក្សាធនាគារកណ្តាលកូរ៉េប្រចាំនៅធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការ អគារសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត ជាផ្លូវការ ស្របពេលដែលរាជរដ្ឋាភិបាលអនុញ្ញាតឱ្យអាជ្ញាធរខេត្តកំពតត្រៀមលក្ខណៈរៀបចំពិធីបុណ្យសមុទ្រ នៅថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ ។ អគាររបស់ធនាគារជាតិនៃកម្ពុជា ខេត្តកំពតនេះ គឺជាផ្នែកមួយនៃការរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងចូលរួមចលនាប្រឡងប្រណាំងទីក្រុងស្អាត របស់រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេស ជាការកសាងសមិទ្ធផលផ្នែកសង្គមនិងវិស័យធនាគារថ្មីមួយបន្ថែមទៀត សម្រាប់ប្រជាជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និវត្តជន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅខេត្តកំពតនិងខេត្តកែបប្រើប្រាស់ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកំពតនិងខេត្តកែប តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរមានសមត្ថកិច្ចជុំវិញខេត្តកំពតនិងខេត្តកែប ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងបង្កបរិយាកាសល្អឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបអាជីវកម្មប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ។ ស្មារតីកិច្ចសហប្រតិបត្តិការជាប្រពៃណីនេះ គឺជាកត្តាគន្លឹះ ធ្វើឱ្យការងាររបស់យើងទទួលបានជោគជ័យជានិច្ច ។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

តាមរយៈរបាយការណ៍របស់ ឯកឧត្តម ខូយ ឃុនហ៊ួរ អភិបាលនៃគណៈអភិបាលខេត្តកំពត និងឯកឧត្តម កែន សត្ថា អភិបាលនៃគណៈអភិបាលខេត្តកែប ខ្ញុំសូមចូលរួមអបអរសាទរចំពោះសមិទ្ធផលអភិវឌ្ឍន៍រីកចម្រើនលើគ្រប់ផ្នែក ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមនៅទូទាំងខេត្ត ។ ខ្ញុំកត់សម្គាល់ឃើញថា ខេត្តនៅជាប់សមុទ្រទាំងពីរនេះជាខេត្តមានសក្តានុពលសេដ្ឋកិច្ចផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម និងនេសាទសមុទ្រដែលអាចផ្គត់ផ្គង់គ្រប់គ្រាន់និងធានាបានសុវត្ថិភាពស្បៀងជាពិសេស ដំណាំស្រូវ ផល្លានុផលផ្លែឈើ ផលិតផលសមុទ្រ និងផលិតផលម្រេចដែលទទួលបានចំណាត់ថ្នាក់លេខ១ជាសកល ។ មិនតែប៉ុណ្ណោះ ខេត្តនេះក៏ជាខេត្តដែលមានសក្តានុពលផ្នែកឧស្សាហកម្មដូចជារោងចក្រផលិតស៊ីម៉ង់ ចំណីសត្វ និងអំបិល និងជាតំបន់ទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ វប្បធម៌ ដែលបានរួមចំណែកលើកស្ទួយវិស័យទេសចរណ៍នៅកម្ពុជា ។ ដោយមានលក្ខខណ្ឌអំណោយផល ខេត្តកំពតនិងខេត្តកែបគឺជាតំបន់គោលដៅសម្រាប់វិនិយោគិនលើវិស័យកសិកម្ម ថាមពលវារីអគ្គិសនី ការអភិវឌ្ឍតំបន់ឆ្នេរ ផលិតកម្មកែច្នៃផលិតផលសមុទ្រ ប្រព័ន្ធធារាសាស្ត្រ អេកូទេសចរណ៍ផងដែរ ។

តាមរយៈរបាយការណ៍របស់លោកនាយកសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពតដែលត្រូវបានសាងសង់ថ្មីនេះ នឹងឆ្លើយតបបានយ៉ាងល្អប្រសើរចំពោះការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចខេត្តនាពេលបច្ចុប្បន្ន និងតម្រូវការចាំបាច់នានា ក្នុងការគ្រប់គ្រងនិងសម្រួលប្រតិបត្តិការរូបិយវត្ថុ សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត ។ អគារនេះត្រូវបានសាងសង់ឡើង ដោយគ្រប់បន្ទប់ធ្វើការបំពាក់នូវប្រព័ន្ធកុំព្យូទ័រ ហើយផ្នែកខាងក្នុងនិងខាងក្រៅអគារត្រូវបានបំពាក់ដោយប្រព័ន្ធសុវត្ថិភាពទំនើប ។ ចាប់ពីថ្ងៃនេះ តទៅ សាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពត នឹងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សេវារូបិយវត្ថុនិងជួយសម្រួលដល់ប្រតិបត្តិការទូទាត់ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទមន្ទីរ-អង្គភាពរបស់រដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាធារណជនទូទៅ ព្រមទាំងធ្វើជាឃ្លាំងផ្ទុកទ្រព្យសម្បត្តិរដ្ឋប្រចាំខេត្តកំពតនិងខេត្តកែប ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបអំពីការអភិវឌ្ឍរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ចនិងវិស័យធនាគារនៅកម្ពុជា ។ ស្ថិតក្នុងបរិយាកាសអំណោយផលនៃសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរកន្លងមក សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ដោយរំពឹងថានឹងសម្រេចបានកំណើន ៦,៩% ក្នុងឆ្នាំ២០១៥ ដែលនឹងធ្វើឱ្យកម្ពុជារួចផុតពីប្រទេសមានចំណូលទាប ហើយក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមនៅឆ្នាំ២០១៦ខាងមុខនេះ ។

កំណើនសេដ្ឋកិច្ចដ៏រឹងមាំនេះ គាំទ្រជាចំបងដោយកំណើននៃការនាំចេញក្នុងឧស្សាហកម្មកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍ ។ អត្រាអតិផរណាមានកម្រិតក្រោម ២% ដែលជាកម្រិតមួយទាប ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក បន្តមានស្ថិរភាពស្ថិតក្នុងរង្វង់ ៤.០០០ រៀលក្នុងមួយដុល្លារ និងប្រែប្រួលបន្តិចបន្តួចទៅតាមរដូវកាលប៉ុណ្ណោះ ។

ចំណែកឯវិស័យធនាគារក៏មានការរីកចម្រើន ទាំងផ្នែកវិសាលភាពនិងទំហំប្រតិបត្តិការ និងបានបន្តគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។ ប្រព័ន្ធធនាគារនៅកម្ពុជា បាននិងកំពុងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ក្នុងការកៀរគរនិងបែងចែកមូលនិធិសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ដោយបំពេញបន្ថែមដើមទុនទៅឱ្យសហគ្រាស ក្រុមហ៊ុន ឬអាជីវកម្មខ្នាតតូចសម្រាប់គម្រោងវិនិយោគនិងពង្រីកផលិតកម្មរបស់ខ្លួន ក្នុងអត្រាការប្រាក់សមរម្យ។ ការផ្តល់និងទទួលបានសេវាឥណទាននិងសេវាហិរញ្ញវត្ថុផ្សេងៗទៀត បានបន្តកើនឡើងជាលំដាប់ ដែលបានបង្ហាញថា សាធារណជនកាន់តែយល់ដឹងច្រើនឡើងពីវប្បធម៌ឥណទាន និងសារៈសំខាន់ក្នុងការស្វែងរកនិងប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុក្នុងជីវភាពប្រចាំថ្ងៃ ក៏ដូចជាទទួលបានសេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយផងដែរ ។

ជាក់ស្តែង តាមរយៈរបាយការថ្មីៗនេះ បានបញ្ជាក់ថា មានប្រជាជនអាយុលើស ១៥ឆ្នាំ ប្រមាណ ៤៦% ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ធៀបនឹង ១៩% កាលពី ៥ឆ្នាំមុន ។ ប្រតិបត្តិការនិងសាខារបស់គ្រឹះស្ថានធនាគារត្រូវបានពង្រីកឥតឈប់ឈររហូតដល់ ៥៨៦ សាខា ព្រមទាំងមានម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) ជាង ១,០០០ កន្លែងនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដើម្បីសម្រួលដល់ការដក ដាក់ និងផ្ទេរប្រាក់របស់ប្រជាពលរដ្ឋ ។ ចំណែកឯទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារបានកើនឡើងដល់ ១៥ពាន់លានដុល្លារអាមេរិក ស្មើនឹង ១០៣% នៃផ.ស.ស ខណៈដែលប្រាក់បញ្ញើបានកើនឡើងដល់ប្រមាណ ១១ ពាន់លានដុល្លារ និងឥណទានចំពោះវិស័យឯកជនក៏បានកើនឡើងដល់ប្រមាណ ១១ពាន់លានដុល្លារអាមេរិកផងដែរ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង មានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយជាឧបករណ៍គោលនយោបាយរដ្ឋាភិបាលសម្រាប់រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូចជូនប្រជាជននិងសហគ្រាសធុនតូចនិងមធ្យម នៅទូទាំងប្រទេស ជាពិសេសនៅតំបន់ជនបទ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនស្របតាមយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។ គួរឱ្យកត់សម្គាល់ថា ក្នុងអំឡុងពេលមួយទស្សវត្សនេះ ទ្រព្យសកម្មវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ពី ១% ដល់ ១៨% នៃផ.ស.ស នៅឆ្នាំ២០១៥ នេះ ។

ក្រៅពីនេះ សេវាកម្មហិរញ្ញវត្ថុថ្មីៗ ក៏កំពុងកកើត និងមានសកម្មភាពយ៉ាងក្លៀវក្លា តួយ៉ាងដូចជាការផ្តល់សេវាកម្មភតិសន្យា សេវាធានារ៉ាប់រងខ្នាតតូចនិងមីក្រូ និងសេវាទូទាត់ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច និងជាពិសេសតាមប្រព័ន្ធទូរស័ព្ទចល័ត Wings ដែលកំពុងចូលរួមយ៉ាងសំខាន់ក្នុងការពង្រីក ការប្រើប្រាស់ និងការទទួលបានសេវាកម្មហិរញ្ញវត្ថុសម្រាប់ប្រជាជននៅតាមជនបទ ។ នៅក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដីគ្រប់ខេត្តក្រុង ដើម្បីផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជាអាជ្ញាធរមានសមត្ថកិច្ច គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាលនិងប្រតិបត្តិករមីក្រូ-ហិរញ្ញវត្ថុ បានជ្រាបពីសារសំខាន់ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាពិសេសសេវាមីក្រូ-ហិរញ្ញវត្ថុ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពសម្រាប់លើកកម្ពស់ជីវភាពរបស់ខ្លួន ហើយជៀសវាងការចាញ់បោកជនឱកាសនិយមដែលធ្វើអាជីវកម្មមិនស្របច្បាប់ ។ ក្នុងនោះ នៅខេត្តកំពត និងខេត្តកែប យើងបានរៀបចំផ្សព្វផ្សាយកាលពីថ្ងៃទី២-៤ ខែមេសា ឆ្នាំ២០១៥ កន្លងមក ។

ស្របពេលគ្នានេះដែរ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុត្រូវបានពង្រឹងនិងបន្តអភិវឌ្ឍជាលំដាប់ ដើម្បីបង្កលក្ខណៈឱ្យកាន់តែប្រសើរសម្រាប់ការរីកចម្រើននៃវិស័យធនាគារ ។ ជាក់ស្តែង ប្រព័ន្ធទូទាត់ជាតិដែលជាស្នូលនៃហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ ក៏ត្រូវបានបង្កើតឡើង ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ដុំ និងរាយដែលកើនឡើងឥតឈប់ឈរទៅតាមការរីកចម្រើននៃសេដ្ឋកិច្ច និងឆ្លើយតបនឹងការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុអាស៊ាន ។ ការអភិវឌ្ឍប្រព័ន្ធទូទាត់នឹងសម្រួលដល់ប្រតិបត្តិការទូទាត់ឱ្យមានសុវត្ថិភាពប្រសិទ្ធភាព ទំនុកចិត្ត និងកាត់បន្ថយចំណាយប្រតិបត្តិការ ។ ចំណែកឯប្រព័ន្ធចែករំលែកព័ត៌មានឥណទានបានបន្តពង្រឹងតម្លាភាព និងជួយកាត់បន្ថយហានិភ័យឥណទានក្នុងប្រព័ន្ធធនាគារ ដែលនឹងរួមចំណែកបង្កើនគុណភាពសំពៀតឥណទាន និងបន្ថយចំណាយលើប្រតិបត្តិការផ្តល់ឥណទាន និងអត្រាការប្រាក់ ។ ក្រៅពីនេះ យើងកំពុងអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ តាមរយៈការជំរុញការប្រើប្រាស់និងជួញដូរមូលបត្រអាចជួញដូរបាន (NCDs) ឱ្យកាន់តែទូលំទូលាយ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ដើម្បីពង្រីកលទ្ធភាពផ្គត់ផ្គង់សន្ទនីយភាព និងបង្កើតឧបករណ៍បន្ថែមសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព ។

ជាទិសដៅទៅខាងមុខ ធនាគារជាតិនៃកម្ពុជានឹងបន្តអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ មានប្រសិទ្ធភាព និងបម្រើផលប្រយោជន៍ប្រជាជន និងសេដ្ឋកិច្ច-សង្គមជារួម ។ ក្នុងនោះផងដែរ យើងនឹងបន្តផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជា ព្រមទាំងបញ្ជ្រាបការអប់រំផ្នែកសេវាហិរញ្ញវត្ថុ

ក៏ដូចជាលើកកម្ពស់ការផ្តល់និងទទួលបានសេវាហិរញ្ញវត្ថុ នៅតាមបណ្តាខេត្ត-ក្រុងនានា ឱ្យកាន់តែទូលំទូលាយ និងយល់ច្បាស់អំពីវប្បធម៌ឥណទាន និងសារៈប្រយោជន៍នៃការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ជាមួយគ្នានេះដែរ ខ្ញុំសូមជម្រាបបន្តិចពីប្រវត្តិនៃការប្រែប្រួលមុខងារនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាថា បន្ទាប់ពីប្រទេសកម្ពុជាយើងបានអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីមក យើងបានកែទម្រង់ប្រព័ន្ធធនាគារពី មួយថ្នាក់ (mono banking) ទៅជាប្រព័ន្ធធនាគារពីរថ្នាក់ (two-tier banking) ។ ហើយការអភិវឌ្ឍនៃប្រព័ន្ធនេះ បានធ្វើឱ្យមានការប្រែប្រួលនូវតួនាទីធនាគារជាតិនៃកម្ពុជាពីដំណាក់កាលមួយទៅដំណាក់កាលមួយផងដែរ ។ នៅទីស្នាក់ការកណ្តាល យើងអនុវត្តគោលនយោបាយផ្សេងៗ ប៉ុន្តែនៅសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស ត្រូវបំពេញមុខងារនិងភារកិច្ចដូចជា ៖

១/- បេឡាររបស់រតនាគារជាតិ

២/- ធនាគាររបស់ធនាគារ ដែលសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេសដើរតួនាទីជាអ្នកផ្តល់សេវាជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣/- អ្នកបែងចែក គ្រប់គ្រង និងកែសម្រួលដល់ចរាចរធនបត្រ និង

៤/- ជាឃ្លាំងទុកដាក់ទ្រព្យសម្បត្តិរបស់រដ្ឋប្រចាំដែនដីនេះ ។

ក្នុងការអនុវត្តមុខងារជាអាជ្ញាធររូបិយវត្ថុ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត នឹងដើរតួនាទីជាភ្នាក់ងារជំរុញការប្រើប្រាស់ប្រាក់រៀល ជាអ្នកសម្របសម្រួលចរាចររូបិយវត្ថុ និងជាអ្នកផ្គត់ផ្គង់សាច់ប្រាក់ឱ្យរតនាគារខេត្ត ធនាគារពាណិជ្ជ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការឬក្រុមហ៊ុន និងសាធារណជននានា សំដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល ស្ថិរភាពថ្លៃ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលបន្ថែមទៀត ។

ក្នុងការអនុវត្តមុខងារជាធនាគាររបស់រដ្ឋាភិបាល និងជាធនាគាររបស់ធនាគារ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត នឹងទទួលបើកគណនីគ្រប់ប្រភេទឱ្យធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងមន្ទីរ-អង្គភាពរដ្ឋ ដើម្បីសម្រួលក្នុងការធ្វើចរាចរសាច់ប្រាក់ និងបម្រើសេវាគ្រប់ប្រភេទ ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ក្រៅពីនេះ សាខារបស់យើងមានភារកិច្ចប្រចាំថ្ងៃរបស់ខ្លួនគឺប្រមូលក្រដាសប្រាក់ចាស់ សឹករេចរឹល ទក់រហែក ហើយដាក់ជំនួសក្រដាសប្រាក់ថ្មីវិញទៅក្នុងចរាចរ ឱ្យស្របតាមតម្រូវការនៃភ្នាក់ងារសេដ្ឋកិច្ចក្នុងខេត្ត ។ ទាំងនេះ គឺជាតួនាទីសំខាន់ របស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត ។

ការរៀបចំកែលម្អសាខាធនាគារជាតិនៃកម្ពុជា មិនត្រឹមតែបង្ហាញពីភាពរឹងមាំនៃវិស័យធនាគារនិងហិរញ្ញវត្ថុដែលមានហេដ្ឋារចនាសម្ព័ន្ធដល់ជនបទប៉ុណ្ណោះទេ ថែមទាំង

ជួយលើកសោភ័ណភាពដល់ខេត្តកំពតទៀតផង ជាពិសេស អគារនេះនឹងធ្វើជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរដ្ឋឱ្យមានសុវត្ថិភាព ។ សាខានេះ ក៏នឹងដើរតួនាទីជាភ្នាក់ងារជំរុញការប្រើប្រាស់ប្រាក់រៀលប្រចាំដែនដី និងអភិវឌ្ឍសេវាកម្មធនាគារនិងហិរញ្ញវត្ថុនៅក្នុងខេត្តឱ្យកាន់តែសម្បូរបែប ហើយប្រជាជននៅទីនេះកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មធនាគារ សម្រាប់បង្កើនជីវភាពប្រចាំថ្ងៃរបស់ខ្លួនកាន់តែប្រសើរឡើង ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

សរុបមក សមិទ្ធផលទាំងនេះ គឺជាសមិទ្ធផលរួមរបស់យើងទាំងអស់គ្នា ដែលកើតឡើងដោយសារមានការចូលរួមសហការល្អ និងការខិតខំប្រឹងប្រែងរបស់អាជ្ញាធរមានសមត្ថកិច្ចប្រចាំដែនដីគ្រប់លំដាប់ថ្នាក់ ហេតុដូច្នេះហើយ ទើបយើងចាត់ទុកសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពតនេះ គឺជាសមិទ្ធផលរួម និង មោទនភាពរួមរបស់យើងទាំងអស់គ្នា ។ សមិទ្ធផលថ្មីនេះ ត្រូវបានកសាងឡើងដើម្បីឆ្លើយតប ទៅនឹងតម្រូវការចាំបាច់របស់អាជ្ញាធរខេត្ត គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភ្នាក់ងារសេដ្ឋកិច្ចនៅក្នុងខេត្តកំពតនិងខេត្តកែប និងជាពិសេសដើម្បីរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ សូមរួមគ្នាជួយថែរក្សា និងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឱ្យមានប្រសិទ្ធភាពនិងស្ថិតស្ថេរយូរអង្វែងតរៀងទៅ ។

ខ្ញុំនៅតែមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាតំណាងអាជ្ញាធរដែនដី មន្ទីរ-អង្គភាពនៅជុំវិញខេត្តកំពតនិងខេត្តកែបទាំងអស់ នៅតែបន្តស្មារតី សហការសាមគ្គីជាប្រពៃណីទាំងកម្លាំងកាយនិងកម្លាំងចិត្ត ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យប្រព្រឹត្តទៅដោយរលូន និងសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត ។ ស្មារតីសាមគ្គីនិងការប្រើកម្លាំងសរុបបែបនេះ គឺជាកត្តាមួយដ៏សំខាន់បំផុតសម្រាប់កំណត់ជ័យជម្នះនិងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមលើគ្រប់វិស័យ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សូមទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ **"អគារ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត"** សម្រាប់ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និវត្តន៍ជន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រជាជនទូទៅនៅក្នុងខេត្តកំពត និងខេត្តកែប ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**